# ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ ជួបឯកឧត្តម ឯកអគ្គរដ្ឋទូត អ៊ីតាលី ប្រចាំកម្ពុជា



នៅព្រឹកថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ២០១៤ ឯកឧត្តម ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានទទួលជួប ឯកឧត្តម **Francesco Saverio Nisio** ឯកអគ្គរដ្ឋទូតនៃប្រទេសអ៊ីតាលីប្រចាំកម្ពុជា ដែលមាននិវេសនដ្ឋាន នៅទីក្រុង បាងកក នៃប្រទេសថៃ ដើម្បីពិភាក្សាការងារ នៅទីស្តីការក្រសួង ។



ឯកឧត្តម **Francesco Saverio Nisio** ឯកអគ្គរដ្ឋទូតនៃប្រទេសអូស្ត្រាលីប្រចាំកម្ពុជា បានជម្រាបជូនពីគោលបំណងនៃជំនួបពិភាក្សា ដោយបានស្នើឱ្យឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ ជួយជម្រុញឱ្យវិស័យឯកជនកម្ពុជា

មានដូចជា វិស័យឧស្សាហកម្មរោងចក្រ វិសហគ្រាសធុនតូច និងមធ្យម ក្នុងការចូលរួមដាក់តាំងបង្ហាញផលិតផលកម្ពុជា ក្នុងពិព័រណ៍ពិភពលោក(World Expo) ដែលនឹងប្រព្រឹត្តិទៅនៅប្រទេសអ៊ីតាលី នាឆ្នាំ២០១៥ ខាងមុខ នេះ ។

ឯកឧត្តមឯកអគ្គរដ្ឋទូត បានបញ្ជាក់ថា:កម្ពុជា មានសេដ្ឋកិច្ចប្រកបដោយសក្តានុពល ជាពិសេសលើវិស័យឧស្សាហកម្មនាំចេញ កសិកម្ម និងទេសចរណ៍ ។ ឯកឧត្តមសង្ឃឹមថា កម្ពុជា នឹងនាំសក្តានុពលទាំងនេះ ទៅបង្ហាញក្នុងពិព័រណ៍ពិភពលោក (World Expo) ដែលនឹងប្រព្រឹត្តិទៅចាប់ពីថ្ងៃទី ០១ ខែ ឧសភា ដល់ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៥ នៅទីក្រុង Milan ប្រទេសអ៊ីតាលី ក្រោមប្រធានបទ " **Feeding the Planet,Energy for Life**" ប្រកបដោយជោគជ័យ ។ ក្នុងនោះ អ៊ីតាលីត្រៀមសម្រួល បែបបទ និងលក្ខណៈងាយស្រួលដែលជាតម្រូវការរបស់កម្ពុជា ។ ទាក់ទងនិងការងារវិនិយោគ ឯកឧត្តម ឯអគ្គរដ្ឋទូតអ៊ីតាលី ក៏បានជម្រាបជូនថា:បច្ចុប្បន្ន អ្នកវិនិយោគអ៊ីតាលី កំពុងសំឡឹងមកលើទីផ្សារនៅអាស៊ី ។ ក្នុងនោះប្រទេសកម្ពុជា ក៏ជាគោលដៅសំខាន់មួយដែរ ។ ជាមួយគ្នានេះ ឯកឧត្តម ឯកអគ្គរដ្ឋទូត បានអញ្ជើញឯកឧត្តមទេសរដ្ឋមន្ត្រី និងប្រតិភូអមដំណើរ ដើម្បីធ្វើទស្សនៈកិច្ចនៅរោងចក្ររបស់សហគ្រិនវ័យក្មេងអ៊ីតាលី ដែលផលិតថាមពលបៃតងនៅកម្ពុជា ។



ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានសម្តែងការស្វាគមន៍ និងបានបញ្ជាក់ថា:ក្នុងអតីត ឯកឧត្តម ជាទេសរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ឯកឧត្តម បានដឹកនាំប្រតិភូចូលរួមតាំងពិព័រណ៍ពិភពលោក បានចំនួន០៣លើក គឺ:ទីក្រុងហេនណូវឺ ប្រទេសអាល្លឺម៉ង់ ទីក្រុង អាយជី ប្រទេស ជប៉ុន និងទីក្រុងសៀងហៃ ប្រទេសចិន ដោយទទួលបានជោគជ័យជានិច្ច ។ ចំពោះពិព័រណ៍ពិភពលោក នាឆ្នាំ២០១៥ ខាងមុខនេះ ក្នុងនាមក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឯកឧត្តមនឹងជួយជម្រុញឱ្យវិស័យឯកជនចូលរួមឱ្យបានច្រើន ជាពិសេសផ្នែកឧស្សាហកម្មនាំចេញ វិស័យសហគ្រាសធុនតូច និងមធ្យម និងផ្នែករោងម៉ាស៊ីនកិនស្រូវជាដើម ។

ឯកឧត្តម បានស្នើឱ្យស្ថានទូត និងសមត្ថកិច្ចអ៊ីតាលី ជួយសម្រួលបែបបទមួយចំនួន ដូចជា ទិដ្ឋាការ និងបែបបទនាំចូលទំនិញតាំងពិព័រណ៍ ជាដើម ហើយឯកឧត្តមក៏បានបញ្ជាក់ថានឹងរកពេលវេលា អញ្ជើញទស្សនកិច្ចសិប្បកម្មបៃតងរបស់អ៊ីតាលី(ផលិតធ្យូងបរិស្ថាន) នាពេលខាងមុខ ។